ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៩ សហវ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មការចំពោះកិច្ចសម្រាប់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបុគ្គលិកមន្ត្រីរាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥.អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា៨ នៃអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីវិធានការចត្តាឡីស័ក ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញសេចក្តីសម្រេចលេខ ២៩ សសរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ (COVID-19)
- បានឃើញសេចក្តីសម្រេចលេខ ២៦ សសរ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ (COVID-19)
- បានឃើញសេចក្តីសម្រេចលេខ ៣៤ សសរ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ (COVID-19)
- បានឃើញសេចក្តីសម្រេចលេខ ០៦០ សខល ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការបង្កើតអនុគណៈកម្មការគ្រប់គ្រងសន្តិសុខនិងសណ្តាប់ធ្នាប់នៅតាមគោលដៅនិងតំបន់ចត្តាឡីស័កដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19)
- បានឃើញសេចក្តីសម្រេចលេខ ៣៧ សសរ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១._**

ត្រូវបានបង្កើតអនុគណៈកម្មការចំពោះកិច្ចសម្រាប់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបុគ្គលិកមន្ត្រីរាជការ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ដែលមានសមាសភាពដូចរាយនាមខាងក្រោម÷

| | | |
|---|---|---|
| ១- **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការ | ប្រធាន |
| ២- **ឯកឧត្តម មាស សុខសេនសាន** | អគ្គលេខាធិការក្រសួង | អនុប្រធាន |
| ៣- **ឯកឧត្តម ហួត ពុំ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤- **ឯកឧត្តម ម៉ី វ៉ាន់** | រដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ៥- **ឯកឧត្តម ចន ឈារិទ្ធ** | អនុរដ្ឋលេខាធិការ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម | សមាជិក |
| ៦-**ឯកឧត្តម ស៊ាន ផល្លា** | អនុរដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម | សមាជិក |

| | | |
|---|---|---|
| **៧-ឯកឧត្តម វង្ស ម៉ុនឥន្ទ្រាវុធ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| **៨-ឯកឧត្តម ហាវ រតនៈ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| **៩-ឯកឧត្តម កែវ ចេងវឡាន់** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុ រដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| **១០-ឯកឧត្តម ឈឹម សារ៉េត** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្ម សាធារណៈ | សមាជិក |
| **១១-ឯកឧត្តម នេត មុន្នី** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិ រដ្ឋនិងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| **១២-ឯកឧត្តម ឈាង វណ្ណារិទ្ធ** | អគ្គនាយកនៃអគ្គនាយដ្ឋានគោលនយោបាយ | សមាជិក |
| **១៣-ឯកឧត្តម អ៊ឹម សិទ្ធីរ៉ា** | អគ្គនាយក នៃអគ្គនាយកដ្ឋានដោះស្រាយ ផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ | សមាជិក |
| **១៤-ឯកឧត្តម ឈួន សំរិទ្ធិ** | អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិ-បត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល | សមាជិក |
| **១៥-ឯកឧត្តម ឆាយ រតនៈ** | អគ្គាធិការ នៃអគ្គាធិការដ្ឋាន | សមាជិក |
| **១៦-ឯកឧត្តម ជា វុធណា** | អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| **១៧-ឯកឧត្តម អ៊ិន អេម** | នាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| **១៨-ឯកឧត្តម ស៊ីសុវត្ថិ ជួងចំន្ទទោ** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈ-កម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា | សមាជិក |
| **១៩-ឯកឧត្តម ម៉ូ ថារិន** | អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម | សមាជិក |
| **២០-លោក កែន សម្បត្តិ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| **២១-លោក ផា អេងទើង** | អគ្គនាយករងនៃអគ្គនាយកដ្ឋាន គយ និងរដ្ឋាករកម្ពុជា | សមាជិក |
| **២២-លោក ខិម ម៉ាក់ធារិទ្ធ** | ប្រធានស្តីទីអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល | សមាជិក |
| **២៣-លោក ចិន កក្កដា** | ប្រធាននាយកដ្ឋានបុគ្គលិក | លេខាធិការ។ |

**ប្រការ២._**

**អនុគណៈកម្មការចំពោះកិច្ចសម្រាប់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបុគ្គលិកមន្ត្រីរាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រង ដឹកនាំ ចាត់ចែងការងារចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈការចូលរួមសហការសម្របសម្រួលគាំទ្រដល់ការងាររបស់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស និងក្រសួងសុខាភិបាល
- គ្រប់គ្រងរៀបចំសម្រង់ស្ថិតិអ្នកស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សហការជាមួយភាគីពាក់ព័ន្ធក្នុងការរៀបចំជូនដំណឹងអំពីនីតិវិធី នៃការចុះឈ្មោះ លក្ខខណ្ឌសុខភាព និងឯកសារនានា ដែលត្រូវភ្ជាប់មកជាមួយនៅពេលចាក់វ៉ាក់សាំង
- ចាត់ចែងរៀបចំនិងផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីកាលវិភាគ ពេលវេលា ទីកន្លែង និងកម្មវិធីចាក់វ៉ាក់សាំងជូនបុគ្គលិកមន្ត្រីរាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សម្របសម្រួលរៀបចំលំហូរ និងយន្តការបច្ចេកទេស និងរដ្ឋបាល ទាំងឡាយណាដែលពាក់ព័ន្ធនឹងដំណើរការចាក់វ៉ាក់សាំងឱ្យប្រព្រឹត្តទៅដោយរលូន និងល្អប្រសើរ
- ចូលរួមធានាសណ្តាប់ធ្នាប់ របៀបរៀបរយ និងគម្លាតសុវត្ថិភាព ជាដើម ក្នុងកំឡុងពេលចាក់វ៉ាក់សាំង តាមរយៈការសហការអនុវត្តផ្អែកលើគោលការណ៍ក្រសួងសុខាភិបាល និងអាជ្ញាធរមានសមត្ថកិច្ច
- គ្រប់គ្រង និងធានាឱ្យមាននូវសម្ភារបរិក្ខារគាំទ្រនានា ក្នុងពេលដំណើរការចាក់វ៉ាក់សាំងជូនបុគ្គលិកមន្ត្រីដែលទៅចាក់វ៉ាក់សាំង ដូចជា ម៉ាស់ អាល់កុល និង/ឬ គ្រឿងឧបភោគបរិភោគ តាមការចាំបាច់
- ត្រៀមលក្ខណៈចូលរួមដោះស្រាយបញ្ហាប្រឈមនានាដែលអាចកើតមានជាយថាហេតុ ក្នុងដំណើរការចាក់វ៉ាក់សាំង ព្រមទាំងពិនិត្យពិគ្រោះយោបល់ និងលើកយោបល់រកវិធានការដោះស្រាយជូនថ្នាក់ដឹកនាំក្រសួង
- ពិនិត្យតាមដានវឌ្ឍភាពនៃដំណើរការចាក់វ៉ាក់សាំងក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជ្រាបតាមការចាំបាច់
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣._**

**អនុគណៈកម្មការចំពោះកិច្ចសម្រាប់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបុគ្គលិកមន្ត្រីរាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** មានសិទ្ធិប្រើប្រាស់បុគ្គលិកមន្ត្រីរាជការបច្ចេកទេសតាមបណ្តាអង្គភាពក្រោមឱវាទក្រសួង តាមរយៈការបែងចែកជាក្រុមការងារ ទៅតាមជំនាញ និងតម្រូវការចាំបាច់ សំដៅធានាកិច្ចដំណើរការចាក់វ៉ាក់សាំងឱ្យប្រព្រឹត្តទៅដោយរលូន ទាន់ពេលវេលា និងប្រសិទ្ធភាព។

**ប្រការ៤._**

អនុប្រធាន និងសមាជិក**អនុគណៈកម្មការចំពោះកិច្ចសម្រាប់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបុគ្គលិកមន្ត្រីរាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន តាមភាពចាំបាច់ជាក់ស្តែង។ ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានជាអ្នកដឹកនាំកិច្ចប្រជុំជំនួស។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៦._**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកអគ្គនាយកដ្ឋាន នាយកខុទ្ទកាល័យ រដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋាន អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ១២ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មេសា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសុខាភិបាល
- គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ